ទីស្ដីការក្រសួងយុត្តិធម៌
លេខ ១១២៣.វណ.កយ-២០០២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>សេចក្ដីណែនាំ</u>

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

<u>**ជម្រាបមក**</u>

**លោកប្រធានតុលាការខេត្ត-ក្រុង**

**លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង**

<u>**សូមជ្រាប។**</u>

<u>**កម្មវត្ថុ:**</u> អំពីការចេញសាលក្រមប្រកាសបណ្ដឹងសម្រេចកែប្រែ ឬ ផ្លាស់ប្ដូរឈ្មោះ ឬ កែប្រែអាយុ ។

<u>**យោង:**</u> សម្រង់សាលក្រមប្រកាសបណ្ដឹងលេខ ១៥(ច) ចុះថ្ងៃទី២៨-០១-២០០២ របស់តុលាការក្រុងភ្នំពេញ ។

-លិខិតលេខ ១៧២ សជណ ចុះថ្ងៃទី១៣-០៩-២០០២ របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

-អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩-១២-២០០០ ស្ដីពីអត្រានុកូលដ្ឋាន ។

-អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២៤-០៦-២០០២ ស្ដីពីការកែសំរួលមាត្រា ៨ និងមាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩-១២-២០០០ ។

-លិខិតលេខ ១០២៨ វណ.កយ ចុះថ្ងៃទី១៨-១០-២០០២ របស់ក្រសួងយុត្តិធម៌ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាគ្រប់ខេត្ត-ក្រុងជ្រាបថា បច្ចុប្បន្ននេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចេញអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩-១២-២០០០ និងអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២៤-០៦-២០០២ ស្ដីពីអត្រានុកូលដ្ឋាន ដែលកំណត់អោយប្រជាពលរដ្ឋរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បំពេញកាតព្វកិច្ចជូនរដ្ឋក្នុងការចុះបញ្ជីជាតិកំណើត ចុះបញ្ជីអាពាហ៍ពិពាហ៍ និងចុះបញ្ជីមរណភាព ។

មាត្រា ១៧ និង មាត្រា ២៥ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩-១២- ២០០០ បានកំណត់ឲ្យប្រជាពលរដ្ឋកម្ពុជា ដែលមានទារកទើបនឹងកើត មានកាតព្វកិច្ចទៅប្ដឹងចុះបញ្ជីជាតិកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានមិនអោយហួសរយៈពេល៣០ថ្ងៃ។ក្នុងករណីទុកអោយហួសរយៈពេល ៣០ថ្ងៃ មន្ត្រីអត្រានុកូលដ្ឋានអាចចុះបញ្ជីកំណើតអោយទារកនោះបានលុះត្រាណាតែមានសាលក្រមពីតុលាការខេត្ត-ក្រុង សាមុី ។

មានត្រា ៥៩ ថ្មី នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២៤-០៦-២០០២ បានកំណត់ថា ការសុំបញ្ជាក់អត្រានុកូលដ្ឋាន ត្រូវបានអនុវត្តន៍ចំពោះតែពលរដ្ឋខ្មែរ ហើយអនុវត្តន៍តែក្នុងរយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃទី០១-០៨-២០០២ ដល់ថ្ងៃទី៣១-០៨-២០០៥ ។ ផុតរយៈពេលនេះ ប្រជាពលរដ្ឋខ្មែរដែល គ្មានសំបុត្រអត្រានុកូលដ្ឋានត្រូវទៅសុំសាលក្រមពីតុលាការខេត្ត-ក្រុង សាមុី ។

ផ្អែកតាមមាត្រាទាំង ៣ នៃអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ដូចបានជម្រាបជូនខាងលើ ដែលកំពុងនៅជាធរមាននេះក្រសួងយុត្តិធម៌បានពិនិត្យឃើញថា អនុក្រឹត្យនេះមានចែងសម្រាប់តែប្រជាពលរដ្ឋកម្ពុជា ដែលមានទារកទើបនឹងកើត ឬ ទើបរៀបអាពាហ៍ពិពាហ៍ ឬ ទើបទទួលមរណភាព រួមជាមួយប្រជាពលរដ្ឋដែលបានចុះបញ្ជីអត្រានុកូលដ្ឋានរួចហើយ ប៉ុន្តែត្រូវបាត់បង់នៅក្នុងរបបប៉ុលពត ឬ ពុំទាន់បានចុះបញ្ជីអតនុកូលដ្ឋាន ចាប់ពីថ្ងៃទី១៧-

០៤-១៩៧៥ រហូតដល់អនុក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិតែប៉ុណ្ណោះដោយពុំមានមាត្រាណាមួយចែងអោយប្រជាពលរដ្ឋកម្ពុជា ប្តឹងសុំអោយតុលាការសម្រេចកែប្រែ ឬ ផ្លាស់ប្តូរឈ្មោះ ឬ កែប្រែអាយុ ខុសពីប្រវត្តិជាតិកំណើតរបស់ខ្លួនឡើយ ។

កន្លងមកក្រសួងយុត្តិធម៌ តែងបានពិនិត្យឃើញតុលាការខេត្ត-ក្រុង មួយចំនួនចេញសាលព្រមប្រកាសបណ្តឹង ដោយសម្រេចសេចក្តីអោយប្រជាពលរដ្ឋ ឬ មន្ត្រីរាជការកែប្រែ ឬ ផ្លាស់ប្តូរឈ្មោះ ឬ កែប្រែអាយុខុសពីប្រវត្តិជាតិកំណើតរបស់ខ្លួនតាមពាក្យប្តឹងសុំរបស់ម្ចាស់បណ្តឹង ដោយពុំមានមូលដ្ឋានច្បាប់ជាបង្អែកឡើយ ដែលជាហេតុធ្វើឱ្យសាលក្រមរបស់តុលាការនោះមានផលប៉ះពាល់ដល់គោលនយោបាយកំណែទម្រង់រដ្ឋបាល របស់រាជរដ្ឋាភិបាលយ៉ាងធ្ងន់ធ្ងរ ។

ដូច្នេះដើម្បីទប់ស្កាត់រាល់សេចក្តីសម្រេចរបស់តុលាការគ្រប់ជាន់ថ្នាក់ ដែលបានសម្រេចតាមអំណាចសាលក្រមប្រកាសបណ្តឹង ដើម្បីកែប្រែ ឬ ផ្លាស់ប្តូរឈ្មោះ ឬ កែប្រែអាយុ តាមពាក្យប្តឹងសុំរបស់ប្រជាពលរដ្ឋ ឬ មន្ត្រីរាជការ ដោយពុំមានមូលដ្ឋានច្បាប់ជាបង្អែកតទៅទៀតនោះ ក្រសួងយុត្តិធម៌សូមលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង បញ្ឈប់នូវការសម្រេចសេចក្តីបែបនេះជាបណ្តោះអាសន្ន រហូតដល់មានច្បាប់កំណត់អំពីគោលការណ៍នេះច្បាស់លាស់សិន ដើម្បីចូលរួមអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាល និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យជូនរដ្ឋ ។

ក្រសួងយុត្តិធម៌សង្ឃឹមថា ប្រធានតុលាការនិងលោកព្រះរាជអាជ្ញាខេត្ត-ក្រុងទាំងអស់ និងទទួលអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ដើម្បីចូលរួមអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋ របស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យពុំខានឡើយ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០២

**រដ្ឋមន្ត្រី**

<u>ចម្លងជូន</u>

-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ខុទ្ទកាល័យព្រឹទ្ធសភា និងរដ្ឋសភា
-ខុទ្ទកាល័យ ទីស្តីការគណៈរដ្ឋមន្ត្រី
-តុលាការកំពូល និង មហាអយ្យការតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការសាលាឧទ្ធរណ៍
-តុលាការ និង អយ្យការយោធា
-ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
-ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
-ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
-ដើម្បីជូនជ្រាប